ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
## ស្តីពី
## ការប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកុម្ភៈ និងទិសដៅការងារខែមីនា ឆ្នាំ២០២០

នាព្រឹកថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង៨:០០ នាទី នៅសាលសិក្ខាសាលាខាងជើង បានបើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារខែកុម្ភៈ និងទិសដៅការងារខែមីនា ឆ្នាំ២០២០ ក្រោមអធិបតីភាព **ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា** ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ និងថ្នាក់ដឹកនាំអង្គភាពចាប់ពីអនុប្រធាននាយកដ្ឋានឡើងចំនួន៨០នាក់។

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមអគ្គលេខាធិការ** បានសម្តែងនូវកិច្ចស្វាគមន៍ចំពោះ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញា ដែលមានវត្តមានក្នុងអង្គប្រជុំ និងបានអនុញ្ញាតឱ្យប្រធាននាយកដ្ឋាន៣រូប មកពីអគ្គនាយកដ្ឋានទាំង៣ឡើងរាយការណ៍លទ្ធផលការងាររបស់នាយកដ្ឋាន និងទិសដៅការងារអនុវត្តបន្តជូនអង្គប្រជុំជ្រាប រួមមាន ៖ ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានស្រាវជ្រាវច្បាប់ និងប្រធាននាយកដ្ឋានព័ត៌មានវិទ្យា ព្រមទាំងទុកឱកាសឱ្យឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ក្នុងអង្គប្រជុំមានសំនួរ ឬផ្តល់មតិណែនាំ ដើម្បីជាប្រយោជន៍រួមក្នុងការបំពេញការងារជូនស្ថាប័ន។

បន្ទាប់ពីបញ្ចប់ដំណើរការធ្វើសេចក្តីរាយការណ៍ស្តីពីលទ្ធផលការងារសម្រេចបានក្នុងខែកុម្ភៈរបស់ប្រធាននាយកដ្ឋានទាំង៣រូប ដែលមកពីអគ្គនាយកដ្ឋានទាំង៣រួចមក ឯកឧត្តមអគ្គលេខាធិការតែងតែធ្លៀតឱកាសដ៏មានតម្លៃជម្រាបជូនអង្គប្រជុំអំពីព្រឹត្តិការណ៍ជាតិ - អន្តរជាតិសំខាន់ៗដែលបានកើតឡើងក្នុងខែកន្លងទៅនេះ ដើម្បីជាចំណេះដឹងជាសាកល ជាពិសេសសម្រាប់ជាជំនួយស្មារតីក្នុងការបំពេញការងារប្រចាំថ្ងៃឱ្យកាន់តែល្អប្រសើរ។



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

I.**លទ្ធផលការងារសម្រេចបានក្នុងខែកុម្ភៈ ឆ្នាំ២០២០**

**១-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយ**

-គណៈកម្មការទី៣ បានអញ្ជើញជួបសវនាការការងារជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីឈ្វេងយល់អំពីបញ្ហាប្រឈម និងសំណូមពរនានា

-គណៈកម្មការទី៥ បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីសកម្មភាពគ្រប់គ្រងច្រកទ្វារព្រំដែន សកម្មភាពចេញ-ចូលរបស់ប្រជាពលរដ្ឋកម្ពុជា និងជនបរទេសដែលឆ្លងកាត់ច្រកទ្វារព្រំដែន នៅខេត្តពោធិ៍សាត់ បាត់ដំបង និងខេត្តប៉ៃលិន

-គណៈកម្មការទី៧ បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីការវិវត្តរីកចម្រើនថ្មី និងបញ្ហាប្រឈមពាក់ព័ន្ធវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង

-គណៈកម្មការទី១០ បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីវិស័យជំនាញរបស់គណៈកម្មការ និងការគ្រប់គ្រងច្រកទ្វារព្រំដែនអន្តរជាតិ នៅខេត្តប៉ៃលិន និងខេត្តបន្ទាយមានជ័យ

-ក្រុមភូមិភាគទី៤ បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីការផ្តល់សេវារដ្ឋបាល ការងារអត្រានុកូលដ្ឋាន ការកែតម្រូវអក្ខរាវិរុទ្ធក្នុងអត្រានុកូលដ្ឋាន មូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ និងការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព នៅខេត្តឧត្តរមានជ័យ។

**២-មុខងារតំណាង**

- សម្តេចប្រធានព្រឹទ្ធសភា បានអញ្ជើញជាអធិបតី និងចូលរួមពិធីផ្សេងៗ៖

-ព្រះរាជពិធីថ្វាយព្រះភ្លើង និងបូជាព្រះបរមសពសម្តេចព្រះធម្មលិខិតកិត្តិបណ្ឌិត **លាស់ ឡាយ** ចិរវិនយោ សម្តេចព្រះសង្ឃនាយករងទី១ ព្រះប្រធានថេរសភា នៃព្រះពុទ្ធសាសនានៅព្រះរាជាណាចក្រកម្ពុជា ព្រះអគ្គាធិការរងពុទ្ធិកសិក្សាជាតិ ឧត្តមប្រឹក្សា ទីប្រឹក្សាជាតិភាសាខ្មែរ ព្រះអនុគណខណ្ឌមានជ័យ នាយកពុទ្ធិកអនុវិទ្យាល័យសន្សំកុសល និងជាព្រះចៅអធិការវត្តសន្សំកុសល

-សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ

ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ និងពិភាក្សាការងារជាមួយអាជ្ញាធរមូលដ្ឋាន ក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងពិធីផ្សេងៗ នៅរាជធានីភ្នំពេញ ខេត្តកណ្ដាល ព្រៃវែង ស្វាយរៀង ព្រះសីហនុ កំពង់ចាម កំពង់ធំ បាត់ដំបង ឧត្តរមានជ័យ និងបន្ទាយមានជ័យ

-ក្រុមភូមិភាគទី២ បានរៀបចំវេទិកាថ្នាក់ស្រុកស្ដីពី ការអនុវត្តតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ និងសហការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន នៅខេត្តកំពង់ចាម

-ក្រុមភូមិភាគទី៤ បានអញ្ជើញសម្ពោធដាក់ឱ្យប្រើប្រាស់អណ្ដូងស្នប់ទឹកស្អាតចំនួន០៤កន្លែងនៅស្រុកបន្ទាយស្រី ខេត្តសៀមរាប

-គណៈកម្មការរៀបចំបុណ្យបញ្ចុះសីមាវត្ត នៅស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ចុះអនុវត្តការងារជាក់ស្ដែង

-ការងារមនុស្សធម៌ ៖ បាននាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តបារាំង ចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ ខេត្តកណ្ដាល ឧត្តរមានជ័យ និងខេត្តបាត់ដំបងៗ

**៣-មុខងារសហប្រតិបត្តិការអន្តរជាតិ**

- សម្ដេចប្រធានព្រឹទ្ធសភា បានទទួលជួបសម្ដែងការគួរសមជាមួយៈ

-ប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

-ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសអូស្ត្រាលី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

-ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋគុយបាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

-ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងសន្និសីទអន្តរជាតិលើកទី២ស្ដីពី ការកសាងខ្សែបន្ទាត់ព្រំដែន សន្តិភាពមិត្តភាព និងសហប្រតិបត្តិការល្អរវាងរណសិរ្សប្រទេសទាំងពីរកម្ពុជា- ឡាវ នៅខេត្តស្ទឹងត្រែង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងវិទ្យាស្ថានចក្ខុវិស័យអាស៊ី (AVI)

-ការចូលរួមពាក់ព័ន្ធនឹងការរៀបចំប្រជុំ ASEP និងទិវា ASEM ។

**៤-មុខងារអភិវឌ្ឍស្ថាប័ន**

-បន្តជួសជុលអគារ DEF អគារជប៉ុន និងសាលពិសេសធំ...។ល។

-បន្តសាងសង់អគារថ្មីកម្ពស់២ជាន់ នៅក្រោយអគារមូលនិធិខ្មែរអភិវឌ្ឍន៍ ការងារបរិស្ថាន និងការដាំដើមឈើបន្ថែម ការងារសន្តិសុខ និងសណ្តាប់ធ្នាប់

-ការរៀបចំរចនាសម្ព័ន្ធ គោលការណ៍ និងគោលនយោបាយថ្មីៗ

-ប្រជុំជាមួយតំណាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រដ្ឋសភា និងក្រុមប្រឹក្សាជម្មនុញ្ញ ពាក់ព័ន្ធផលប្រយោជន៍មន្ត្រីរាជការ៣ស្ថាប័ន

-ប្រជុំការងារទូទៅជាមួយលេខាធិការដ្ឋានអមគណៈកម្មការទាំង១០ព្រឹទ្ធសភា

-ប្រជុំបូកសរុបលទ្ធផលការងារ ព្រមទាំងកំណត់ទិសដៅការងារបន្ត និងសភាពការណ៍ថ្មីៗ (ពីរកំរិតៈ កំរិតនាយកដ្ឋាន និងកំរិតការិយាល័យ)

-អនុវត្តការងារលទ្ធកម្មសាធារណៈឆ្នាំ២០២០ និងការចាប់ផ្តើមកាត់ឯកសណ្ឋានជូនមន្ត្រីរាជការ

-កិច្ចប្រជុំក្រុមប្រឹក្សាភិបាល PIC ដើម្បីកំណត់ផែនការសកម្មភាព និងថវិកាអនុវត្តឆ្នាំ ២០២០ ព្រមទាំងផែនការ PCA ក្នុងឆ្នាំ២០២០។

**៥-ការបណ្តុះបណ្តាលធនធានមនុស្ស**

-បានបើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន ០៤វគ្គ សិក្ខាកាមចំនួន១០០នាក់

-បានទទួលដំណើរទស្សនកិច្ចសិក្សារបស់មន្ត្រីទីចាត់ការការងារព្រំដែនអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទចំនួន២៥នាក់

-បានរៀបចំបាឋកថាស្តីពីការអប់រំផ្នត់គំនិត

-ប្រជុំពិនិត្យលើការរៀបចំគោលនយោបាយអភិវឌ្ឍធនធានមនុស្ស របស់អគ្គលេខាធិ-ការដ្ឋានព្រឹទ្ធសភា។

**II.ទិសដៅការងារសម្រាប់ខែមីនាឆ្នាំ២០២០**

១-សេវាទ្រទ្រង់មុខងារនីតិកម្ម ៖

-ព្រឹទ្ធសភាវិស្សមកាលពីថ្ងៃទី២៣ ខែមករា ដល់ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០

-ខុទ្ទកាល័យថ្នាក់ដឹកនាំទាំង៣ លេខាធិការដ្ឋានអមគណៈកម្មការទាំង១០ និងអង្គភាពពាក់ព័ន្ធ ត្រៀមផ្តល់របាយការណ៍ចន្លោះសម័យប្រជុំព្រឹទ្ធសភាលើកទី៤ និងទី៥ នីតិកាលទី៤ ឱ្យបានទាន់ពេលវេលា

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៤ ដើម្បីពិនិត្យ និងឱ្យយោបល់លើ៖

១.សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

២.សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

៣.គម្រោងអភិវឌ្ឍរោងចក្រអគ្គិសនីដុតធ្យូងថ្ម២៦៥មេហ្គាវ៉ាត់ នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ គម្រោងអភិវឌ្ឍបណ្តាញបញ្ជូន២៣០គីឡូវ៉ុល ពីរោងចក្រអគ្គិសនីធ្យូងថ្មខេត្តឧត្តរមានជ័យ មកអនុស្ថានីយសៀមរាប និងគម្រោងអភិវឌ្ឍរោងចក្រអគ្គិសនីដុតធ្យូងថ្ម៧០០មេហ្គាវ៉ាត់ នៅស្រុកបុទុមសាគរ ខេត្តកោះកុង និងការអនុវត្តបន្តទៀត

៤.បញ្ហាផ្សេងៗសំណើសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិលើ៖

៤.១-សន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

៤.២-សន្ធិសញ្ញាស្តីពីការផ្ទេរទណ្ឌិត រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

៤.៣-ពិធីសារទីមួយ ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន

៤.៤-ពិធីសារទីពីរ ស្តីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន

៤.៥-ពិធីសារទីបី ស្តីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន។

**២-សេវាទ្រទ្រង់មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយ**

-ត្រៀមសហការ និងសម្របសម្រួលការងារជូនគណៈកម្មការជំនាញជួបសវនាការជាមួយ

ក្រសួង-ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា រួមមាន៖

+គណៈកម្មការទី១ ចុះបេសកកម្ម ដើម្បីឈ្វេងយល់អំពីការអនុវត្តសិទ្ធិមនុស្ស ការអនុវត្តន៍ច្បាប់ និងការដោះស្រាយពាក្យបណ្តឹងថ្នាក់ក្រោមជាតិ ព្រមទាំងផ្សព្វផ្សាយសិទ្ធិ និងករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ នៅខេត្តកំពង់ធំ ព្រះវិហារ ឧត្តរមានជ័យ និងខេត្តសៀមរាប (២២-២៨/៣/២០២០)

+គណៈកម្មការទី២ ចុះបេសកកម្ម ដើម្បីឈ្វេងយល់អំពីការអភិវឌ្ឍប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្នុងបុព្វបទថ្មី ពិសេសការផ្ទេរចាត់ចែងការអនុវត្តថវិកា ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈ នៅខេត្តពោធិ៍សាត់ (០១-០៥/៣/២០២០)

+គណៈកម្មការទី៣ ចុះបេសកកម្ម ទៅខេត្តកំពង់ស្ពឺ (០៩/៣/២០២០)

+គណៈកម្មការទី៤ ចុះបេសកកម្ម ដើម្បីឈ្វេងយល់អំពីប្រសិទ្ធភាពក្នុងការអនុវត្តន៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត នៅខេត្តបន្ទាយមានជ័យ (១១-១៣/៣/២០២០)

+គណៈកម្មការទី៦ ចុះបេសកកម្ម នៅខេត្តកណ្តាល (១៨-១៩/៣/២០២០)

+គណៈកម្មការទី៨ ចុះបេសកកម្ម ដើម្បីឈ្វេងយល់អំពីបញ្ហាសុខភាពសាធារណៈ នៅខេត្តស្ទឹងត្រែង រតនគិរី និងខេត្តមណ្ឌលគិរី (សប្តាហ៍ទី៤/៣/២០២០)

+គណៈកម្មការទី៩ ចុះបេសកកម្ម ដើម្បីឈ្វេងយល់អំពីវិស័យពាក់ព័ន្ធ នឹងសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តព្រះសីហនុ (០២-០៦/៣/២០២០) ។

**៣-សេវាទ្រទ្រង់មុខងារតំណាង៖**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ

-ត្រៀមពិធីកាត់ឫសសីមាព្រះវិហារ នៅស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង

-ត្រៀមប្រារព្ធទិវាអន្តជាតិនារី ៨មីនា ឆ្នាំ២០២០ ក្រោមប្រធានបទ " មានសន្តិភាព មាន

ការលើកកម្ពស់សមភាពយេនឌ័រ " (គណៈប្រតិភូក្រសួងកិច្ចការនារី និងផ្នែកក្នុងអគ្គលេខាធិ-ការដ្ឋានព្រឹទ្ធសភា)

-ត្រៀមពិធីអបអរបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ។

**៤-កិច្ចសហប្រតិបត្តិការអន្តរជាតិ៖**

-ត្រៀមរៀបចំពិធីជំនួបផ្លូវការរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូជាតិ និងអន្តរជាតិនានា ព្រមទាំងអគ្គទូត (ទូតអ៊ីស្រាអែល)

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ព្រមទាំងមន្ត្រីអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា បំពេញបេសកកម្មក្រៅប្រទេស

-ត្រៀមរៀបចំទិវាហ្វ្រង់កូហ្វូនីប្រចាំឆ្នាំ(ខួបលើកទី៥០)នៅព្រឹទ្ធសភា(២០មីនា ឆ្នាំ២០២០)

-ត្រៀមចូលរួមមហាសន្និបាតលើកទី១៤៣ របស់សហភាពអន្តរសភាIPU (១៣-២០/៤/២០២០)

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា

-ការចូលរួមជាមួយរដ្ឋសភាដើម្បីរៀបចំ ASEP ឆ្នាំ២០២០ និង ASEM Day (១០/០៣/២០២០)។

**៥-ការអភិវឌ្ឍស្ថាប័ន៖**

-បង្កើនការគ្រប់គ្រងអគារ សារពើភ័ណ្ឌ និងការគ្រប់គ្រងសន្តិសុខសណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃ ទឹក ភ្លើង ការគ្រប់គ្រងការប្រើប្រាស់ INTERNET

-បន្តកែលម្អហេដ្ឋារចនាសម្ព័ន្ធនៅក្នុងព្រឹទ្ធសភា

-បន្តកែលម្អបរិស្ថាននៅក្នុងបរិវេណព្រឹទ្ធសភា

-រៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋានគណៈកម្មការ និងក្រុមនានា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាលកម្មវិធី Eបណ្ណាល័យ និងEបណ្ណសារ

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍ពីប្រកពប្រទេសផ្សេងៗទៀត (ឆ្នាំ២០២០)

-បន្តកសាង និងធ្វើបច្ចុប្បន្នភាពគោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត

បម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកំណែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការផ្សេងៗ

-បន្តសហការជាមួយក្រុមការងារគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា(FMIS) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងចូលរួមសិក្ខាសាលានានា

-រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍ ICT អភិវឌ្ឍធនធានមនុស្ស ព័ត៌មាននិងទំនាក់ទំនងសាធារណៈ ការស្រាវជ្រាវ និងសហប្រតិបត្តិការអន្តរជាតិ

-បន្តប្រជុំគណៈកម្មការគោលការណ៍ គោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បង្កើនការបញ្ចូលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្នុងគ្រប់វិស័យការងាររបស់ស្ថាប័ន

-រៀបចំផែនការបណ្តុះបណ្តាលមន្ត្រីខេមរភាយ និងពិបាកដោយផ្សារភ្ជាប់វិធានការអប់រំរដ្ឋបាល និងច្បាប់ និងអភិក្រមទាំង៥

-បន្តរៀបចំក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងរយៈពេល១០ឆ្នាំទៅមុខ (២០២០-២០៣០)

-ត្រៀមប្រជុំវាយតម្លៃផែនការប្រតិបត្តិគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំត្រីមាសទី១ ឆ្នាំ២០២០

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការផ្សេងៗ។

**សេចក្តីសន្និដ្ឋាន**

ខែកុម្ភៈនេះ ព្រឹទ្ធសភាស្ថិតក្នុងអំឡុងពេលវិស្សមកាល។ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានផ្តោតការយកចិត្តទុកដាក់ខ្ពស់ ជាអាទិភាពលើមុខងារតាមដានការអនុវត្តច្បាប់ ដោយបានផ្តល់សេវាជូនគណៈកម្មការជំនាញទាំង១០ ចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុង និងជួបសវនាការការងារជាមួយក្រសួងនានាបានយ៉ាងល្អប្រសើរ។ ចំពោះមុខងារតំណាង បានដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ រៀបចំវេទិកា និងអមដំណើរសមាជិកព្រឹទ្ធសភាចុះតាមមូលដ្ឋាន ដើម្បីឈ្វេងយល់អំពីសុខទុក្ខ ដោះស្រាយបញ្ហាប្រឈម និងសំណូមពរនានារបស់ប្រជាពលរដ្ឋ។ ចំពោះការអភិវឌ្ឍ

ស្ថាប័ន បានខិតខំកែសម្រួលរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឲ្យបានកាន់តែសមស្របតាមបរិបទថ្មីបន្ថែមទៀត។ ទន្ទឹមនឹងនេះ ការបង្កើនសមត្ថភាពស្រាវជ្រាវ ការប្រើប្រាស់ប្រព័ន្ធ ICT ក្នុងការអនុវត្តការងារប្រចាំថ្ងៃ និងខិតខំជំរុញការផ្តល់សេវាឱ្យបានគាប់ប្រសើរ ហើយបន្តខិតខំកែលម្អសេវាទាំងឡាយ ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជាអតិបរមា ដើម្បីកាត់បន្ថយការប្រើប្រាស់ក្រដាស។ ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ព្រឹទ្ធសភាបានចូលរួមអនុវត្តគោលនយោបាយពង្រឹងទំនាក់ទំនងខាងក្នុង និងពង្រីកទំនាក់ទំនងខាងក្រៅ ដើម្បីបង្កើនជំនឿទុកចិត្តឱ្យបានខ្ពស់ពីសំណាក់ដៃគូទាំងអស់របស់ព្រឹទ្ធសភា ក្នុងន័យបង្កើនកិច្ចសហប្រតិបត្តិការឱ្យកាន់តែប្រកបដោយផ្លែផ្កាថែមទៀត។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១០.៤៥ នាទីព្រឹក ក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល ប្រកបដោយស្មារតីទទួលខុសត្រូវ។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០

ប្រធាននាយកដ្ឋាន

ឡាំង ថន

បានឃើញ និងឯកភាព
អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ

បានឃើញ និងឯកភាព
អគ្គលេខាធិការស្តីទី

ឡោក_ឆាយ